# មហាធម្មបាលជាតក

## ( ធម្មោ ហវេ រក្ខតិ ធម្មចារឹ ធម៌រមែងរក្សានូវអ្នកប្រព្រឹត្តធម៌)




*ព្រះសាស្ដាកាលយាងទៅកបិលបុរី ដោយការយាងទៅជាដំបូង ស្ដេចគង់នៅវត្តនិគ្រោធារាម ទ្រង់ប្រារព្ធនូវការមិនជឿ របស់ព្រះបិតាក្នុងព្រះរាជនិវេសន៍ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **កឹ តេ វតំ** *ដូច្នេះជាដើម ។*

*ក្នុងគ្រានោះ[១] ព្រះបាទសុទ្ធោទនមហារាជថ្វាយយាគូ និងបង្អែមដល់ព្រះមានព្រះភាគ និងព្រះភិក្ខុជាបរិវារ ២ ម៉ឺនអង្គ ក្នុងរាជនិវេសន៍របស់ខ្លួន កាលពោលសម្មោទនីយកថា[២]*

---

*១. ប្រហែលជាថ្ងៃទី៨ នៃការយាងមកដល់របស់ព្រះពុទ្ធ សូមជម្រាបថា ព្រះនន្ទបួសក្នុងថ្ងៃទី ៣ ព្រះរាហុលបួសក្នុងទី ៧ ព្រះបាទសុទ្ធោទនៈយាងទៅសូមពរមិនឲ្យបំបួសបុត្រដែលមាតាបិតាមិនអនុញ្ញាត ហើយទូលសូមនិមន្តឲ្យព្រះអង្គឆាន់ក្នុងថ្ងៃស្អែក ។ ២. សម្ដីដែលគួររីករាយ, គួរគ្រេកអរ; សម្ដីរាក់ទាក់, រួសរាយ ។*

*ក្នុងវាំងចន្ទោះភត្ត បានត្រាស់ថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលដែលទ្រង់ធ្វើសេចក្តីទុក្ករ-កិរិយា មានទេវតាមកឋិតនៅលើអាកាស ហើយពោលប្រាប់ខ្ញុំព្រះអង្គថា ព្រះសិទ្ធត្ថកុមារជាបុត្ររបស់ព្រះអង្គស្លាប់ហើយ ព្រោះភាពជាអ្នកមានអាហារតិច ។ ព្រះសាស្តាសួរថា បពិត្រមហារាជ តើទ្រង់ជឿទេ ? ព្រះរាជាសុទ្ធោទនៈត្រាស់ថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនជឿទេវតាដែលឋិតនៅលើអាកាសពោលនោះទេ ខ្ញុំព្រះអង្គពោលហាមឃាត់ថា បុត្ររបស់យើង កាលនៅមិនទាន់ត្រាស់ជាព្រះពុទ្ធ ឈ្មោះថា ការបរិនិព្វាន រមែងមិនមាន ។ ព្រះសាស្តាត្រាស់ថា បពិត្រមហារាជ ឥឡូវនេះ ព្រះអង្គនឹងជឿដូចម្តេចកើត សូម្បីក្នុងកាលមុនកាលតថាគតនៅជាមហាធម្មបាល កាលអាចារ្យទិសាបាមោក្ខពោលថា បុត្ររបស់លោកស្លាប់ហើយ នេះជាឆ្អឹងរបស់គេ ព្រះអង្គមិនបានជឿហើយពោលថា ឈ្មោះថា ការស្លាប់ក្នុងវ័យក្មេង របស់មនុស្សក្នុងត្រកូលរបស់ខ្ញុំ រមែងមិនមាន ដូច្នេះហើយ ព្រះទសពលដែលព្រះរាជាទូលអារាធនាហើយ ទើបទ្រង់នាំអតីតនិទានមកសម្តែងថា*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី មានស្រុកមួយឈ្មោះ **ធម្មបាលគ្រាម** ក្នុងដែនកាសី ។ ស្រុកនោះមានឈ្មោះយ៉ាងនោះ ព្រោះជាទីនៅរបស់ត្រកូលធម្មបាលព្រាហ្មណ៍ ។ ព្រាហ្មណ៍ក្នុងត្រកូលនោះ មានឈ្មោះថា **ធម្មបាល** ព្រោះជាអ្នករក្សាកុសលកម្មបថ ១០ មនុស្សទាំងអស់ក្នុងត្រកូលនោះ ដោយហោចទៅសូម្បីតែទាសកម្មករ ក៏តែងតែឲ្យទាន រក្សាសីល និងធ្វើឧបោសថកម្មដែរ ។ គ្រានោះ ព្រះពោធិសត្វកើតក្នុងត្រកូលធម្មបាលនោះ ពពួកញាតិទាំងឡាយដាក់ឈ្មោះ ដល់ព្រះពោធិសត្វនោះថា **ធម្មបាលកុមារ** ។*

*លំដាប់នោះ កាលចម្រើនវ័យធំហើយ បិតាបានឲ្យទ្រព្យមួយពាន់ ហើយបញ្ជូនទៅនគរតក្កសិលា ដើម្បីប្រយោជន៍ដល់ការសិក្សាសិល្បសាស្ត្រ ។ ព្រះពោធិសត្វទៅកាន់នគរតក្កសិលានោះ ហើយសិក្សាសិប្បវិជ្ជាក្នុងសម្នាក់អាចារ្យទិសាបាមោក្ខ លោកបានជាប្រធាននៃមាណពជាអន្តេវាសិក ៥០០ នាក់ ។ គ្រានោះ បុត្រច្បងរបស់អាចារ្យធ្វើកាលកិរិយា ។*

អាចារ្យដែលពួកមាណពចោមរោម កាលទួញសោកមួយអន្ទើដោយពួកញាតិ បានធ្វើសរីរ-កិច្ចរបស់បុត្រនោះ ក្នុងព្រៃស្មសាន ។ អាចារ្យ និងសិស្សទាំងឡាយ ព្រមទាំងពពួកញាតិ យំស្រែក បរិទេវនាការក្នុងទីនោះ មានតែធម្មបាលកុមារម្នាក់ប៉ុណ្ណោះ ដែលមិនបានយំសោកបរិទេវនាការឡើយ ។ បន្ទាប់មក កាលមាណពទាំង ៥០០ មកពីព្រៃស្មសាន ទៅអង្គុយក្នុងសម្នាក់អាចារ្យ បានពោលថា ឱហ្ន៎ មិនគួរសោះ មាណពកំលោះដែលដល់ព្រមដោយអាចារៈមានសភាពបែប បានដល់នូវមរណៈ ព្រាត់ប្រាសចាកមាតាបិតា ក្នុងកាលនៅក្មេងប៉ុណ្ណោះ ។ ធម្មបាលកុមារពោលថា នែសម្លាញ់ អ្នកទាំងឡាយពោលថា នៅក្មេងឬ ព្រោះហេតុអ្វីបានជាស្លាប់ក្នុងវ័យក្មេង មិនគួរស្លាប់ក្នុងវ័យក្មេងឡើយ ។

លំដាប់នោះ ពួកមាណពពោលនឹងធម្មបាលថា នែសម្លាញ់ អ្នកនិយាយអ្វី អ្នកមិនដឹងមរណភាពនៃសត្វទាំងឡាយនេះឬ ? ធម្មបាលពោល ខ្ញុំដឹង តែមិនគួរស្លាប់ក្នុងកាលក្មេងសោះ គួរតែស្លាប់ក្នុងវ័យចាស់ប៉ុណ្ណោះ ។ មាណពទាំងឡាយពោលថា សង្ខារទាំងឡាយមិនទៀង មានហើយ ត្រឡប់ជាមិនមាន មិនមែនឬ ? ធម្មបាលពោលថា ពិតហើយ សង្ខារទាំងឡាយមិនទៀង តែសត្វទាំងឡាយមិនត្រូវស្លាប់ក្នុងកាលក្មេងឡើយ ត្រូវស្លាប់ក្នុងវ័យចាស់ ក៏ដល់ការមិនទៀងដែរ ។ មាណពទាំងឡាយពោលថា នែធម្មបាលសម្លាញ់ អ្នកនិយាយអ្វី ក្នុងផ្ទះរបស់អ្នក មិនមានអ្នកស្លាប់ឬ ? ធម្មបាលពោលថា ក្នុងផ្ទះរបស់ខ្ញុំមិនមានអ្នកស្លាប់ក្នុងកាលក្មេងទេ ស្លាប់តែក្នុងកាលចាស់ប៉ុណ្ណោះ ។ មាណពទាំងឡាយពោលថា នេះជាប្រពៃណីត្រកូលរបស់អ្នកឬ ?ធម្មបាលពោលថា បាទ នេះជាប្រពៃណីត្រកូលរបស់ខ្ញុំ ។ មាណពទាំងឡាយបានស្តាប់ពាក្យរបស់ធម្មបាលនោះហើយ ក៏ប្រាប់ដល់អាចារ្យ ។

គ្រានោះ អាចារ្យឲ្យហៅធម្មបាលមកហើយសួរថា នែធម្មបាលកូន បានឮថា ក្នុងត្រកូលរបស់អ្នក មិនមានអ្នកស្លាប់ក្នុងកាលក្មេង ពិតមែនឬ ? ធម្មបាលឆ្លើយថា ពិតមែនហើយ លោកអាចារ្យ ។ អាចារ្យនោះស្តាប់ពាក្យរបស់ធម្មបាលហើយ គិតថា កុមារនេះនិយាយពាក្យអស្ចារ្យក្រៃលែងណាស់ យើងនឹងទៅកាន់សម្នាក់បិតារបស់គេហើយសួរមើលបើពិតយ៉ាងនោះ សូម្បីយើងនឹងបំពេញធម៌នោះដែរ ។ លោកអាចារ្យធ្វើឈាបនកិច្ចរបស់បុត្រហើយ ដោយកាលកន្លងទៅ ៧, ៨ ថ្ងៃ បានឲ្យគេហៅធម្មបាលមកហើយ ប្រាប់ថា នែកូន

យើងនឹងមកវិញដោយឆាប់ អ្នកចូលប្រាប់សិប្បៈដល់មាណពទាំងឡាយ ដរាបដល់យើងត្រឡប់មក ដូច្នេះហើយ គាត់បានកាន់យកឆ្អឹងពពែមួយ មកលាងជម្រះ ហើយដាក់ការុងកាន់យកអ្នកបម្រើម្នាក់ ចេញពីនគរតក្កសិលា ទៅដល់ស្រុកនោះដោយលំដាប់ ហើយសួរគេថា ណាមួយជាផ្ទះរបស់មហាធម្មបាល ? កាលបានដឹងហើយក៏ទៅ ឋិតនៅត្រង់ទ្វារ ។

ពួកមនុស្សជាទាសៈណាៗ របស់ព្រាហ្មណ៍ដែលឃើញមុន មនុស្សនោះៗ នាំគ្នាទទួលឆត្រ និងស្បែកជើងអំពីដៃរបស់អាចារ្យ និងទទួលការុងពីដៃរបស់អ្នកបម្រើអាចារ្យនោះ ។ កាលអាចារ្យពោលថា ពួកអ្នកចូរប្រាប់បិតារបស់កុមារថា អាចារ្យរបស់ធម្មបាលកុមារដែលជាបុត្ររបស់លោក មកហើយឈរនៅត្រង់ទ្វារ ។ មនុស្សទាំងឡាយទទួលថា ល្អ ហើយនាំគ្នាទៅប្រាប់ដល់ព្រាហ្មណ៍ ។ ព្រាហ្មណ៍នោះប្រញាប់ទៅកាន់ទ្វារ ហើយអញ្ជើញអាចារ្យថា លោកចូរមកចុះ ហើយនាំព្រាហ្មណ៍នោះចូលផ្ទះ ឲ្យអង្គុយលើបល្ល័ង្ក និងធ្វើកិច្ចទាំងពួងមានការជម្រះជើងជាដើម ។

អាចារ្យបរិភោគភោជនហើយ កាលអង្គុយសន្ទនាដោយពាក្យជាសុខ ទើបពោលថា ម្នាលព្រាហ្មណ៍ ធម្មបាលកុមារដែលជាបុត្ររបស់លោក ជាអ្នកមានបញ្ញា បានដល់ការសម្រេចនូវត្រៃវេទ និងសិល្បសាស្ត្រទាំង ១៨ ប៉ុន្តែគេបានស្លាប់ហើយ ដោយរោគមិនជាសប្បាយណាមួយ សង្ខារទាំងពួងមិនទៀង សូមលោកកុំសោយសោកឡើយ ។ ព្រាហ្មណ៍ទះបាតដៃ ហើយសើចដ៏ខ្លាំងៗ ។ អាចារ្យសួរថា ម្នាលព្រាហ្មណ៍ ហេតុដូចម្ដេច បានជាលោកសើច ? ព្រាហ្មណ៍ពោលថា បុត្ររបស់ខ្ញុំមិនស្លាប់ទេ អ្នកដែលស្លាប់នោះជាមនុស្សដទៃ ។ អាចារ្យពោលថា ម្នាលព្រាហ្មណ៍ បុត្ររបស់លោកស្លាប់ហើយ លោកបានឃើញឆ្អឹងបុត្ររបស់លោកហើយនឹងជឿ ដូច្នេះហើយអាចារ្យនោះ បាននាំឆ្អឹងចេញមក ហើយពោលថា នេះជាឆ្អឹងបុត្ររបស់លោក ។ ព្រាហ្មណ៍ពោលថា នេះជាឆ្អឹងរបស់ពពែ ឬសុនខ បុត្ររបស់ខ្ញុំមិនស្លាប់ទេ ព្រោះក្នុងត្រកូលរបស់ខ្ញុំ អស់ ៧ ជួរមកហើយ មិនមានអ្នកស្លាប់ក្នុងកាលនៅក្មេងទេ លោកនិយាយកុហក ។ ក្នុងខណៈនោះ មនុស្សទាំងឡាយនាំគ្នាទះដៃ ហើយសើចយ៉ាងខ្លាំង ។ អាចារ្យឃើញភាពអស្ចារ្យនោះហើយ ជាអ្នកដល់ព្រមដោយសេចក្ដីសោមនស្សកាលនឹងសួរថា ម្នាលព្រាហ្មណ៍ ក្នុងកុលបវេណីរបស់លោក ដែលមនុស្សក្មេងៗ មិនស្លាប់ បើ

*មិនមានហេតុ មិនអាចប្រព្រឹត្តទៅបានទេ ចុះព្រោះហេតុអ្វី បានជាក្មេងទាំងឡាយ មិនស្លាប់ ដូច្នេះហើយ ទើបពោលគាថាទី ១ ថា*

**កឹំ តេ វតំ កឹំ បន ព្រហ្មចរិយំ, កិស្ស សុចិណ្ណស្ស អយំ វិបាកោ;**
**អក្ខាហិ មេ ព្រាហ្មណ ឯតមត្ថំ, កស្មា នុ តុម្ហំ ទហរា ន មីយរេ។**

***អ្វីជាវត្តរបស់អ្នក អ្វីជាព្រហ្មចរិយៈរបស់អ្នក នេះជាផលសុចរិតធម៌ ដូចម្តេច ដែលអ្នកសន្សំល្អហើយ ម្នាលព្រាហ្មណ៍ អ្នកចូរប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ ព្រោះហេតុអ្វី ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់អ្នក មិនស្លាប់ ។***

*ពាក្យថា **វត្ត** បានដល់ ការសមាទានកិច្ចប្រព្រឹត្តបដិបត្តិ ។ ពាក្យថា **ព្រហ្មចរិយៈ** បានដល់ ការប្រព្រឹត្តដ៏ប្រសើរ ។ ពាក្យថា **នេះជាផលសុចរិតធម៌ ដូចម្តេច ដែលអ្នកសន្សំល្អហើយ** សេចក្តីថា ការដែលក្មេងៗទាំងឡាយក្នុងត្រកូលរបស់អ្នកមិនស្លាប់នេះ ជាផលនៃសុចរិតធម៌អ្វី ?*

*ព្រាហ្មណ៍ស្តាប់ពាក្យនោះហើយ កាលពណ៌នាអានុភាពនៃគុណ ដែលធ្វើឲ្យក្មេងៗទាំងឡាយក្នុងត្រកូលមិនស្លាប់ ទើបពោលគាថាទាំងនេះថា*

**ធម្មំ ចរាម ន មុសា ភណាម, បាបានិ កម្មានិ បរិវជ្ជយាម;**
**អនរិយំ បរិវជ្ជមុ សព្វំ, តស្មា ហិ អម្ហំ ទហរា ន មីយរេ។**

***ពួកយើងប្រព្រឹត្តធម៌ មិននិយាយកុហក វៀរនូវអំពើដ៏លាមក វៀរនូវអំពើមិនប្រសើរគ្រប់យ៉ាង ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើងមិនស្លាប់ ។***

**សុណោម ធម្មំ អសតំ សតញ្ច, ន ចាបិ ធម្មំ អសតំ រោចយាម;**
**ហិត្វា អសន្តេ ន ជហាម សន្តេ, តស្មា ហិ អម្ហំ ទហរា ន មីយរេ។**

ពួកយើងស្តាប់ធម៌ របស់អសប្បុរសផង សប្បុរសផង ប៉ុន្តែពួកយើង មិនពេញចិត្តនឹងធម៌របស់ពួកអសប្បុរសទេ ពួកយើងលះបង់អសប្បុរស មិនលះបង់សប្បុរសទេ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើង មិនស្លាប់ ។

បុព្វេវ ទានា សុមនា ភវាម, ទទម្បិ វេ អត្តមនា ភវាម;
ទត្វាបិ វេ នានុតប្បាម បច្ឆា, តស្មា ហិ អម្ហំ ទហរា ន មីយរេ។

ពួកយើងមានចិត្តល្អ ក្នុងកាលមុនឲ្យ កាលកំពុងឲ្យ ក៏មានចិត្តត្រេកអរ លុះឲ្យហើយ មិនក្តៅក្រហាយក្រោយ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើង មិនស្លាប់ ។

សមណេ មយំ ព្រាហ្មណេ អទ្ធិកេ ច, វនិព្វកេ យាចនកេ ទលិទ្ទេ;
អន្នេន បានេន អភិតប្បយាម, តស្មា ហិ អម្ហំ ទហរា ន មីយរេ។

ពួកយើងបានញ៉ាំងពួកសមណព្រាហ្មណ៍ អ្នកដំណើរ ស្មូម យាចក និងអ្នកកម្សត់ ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយ និងទឹក ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់យើង មិនស្លាប់ ។

មយញ្ច ភរិយំ នាតិក្កមាម, អម្ហេ ច ភរិយា នាតិក្កមន្តិ;
អញ្ញត្រ តាហិ ព្រហ្មចរិយំ ចរាម, តស្មា ហិ អម្ហំ ទហរា ន មីយរេ។

ពួកយើងមិនប្រព្រឹត្តកន្លងចិត្តភរិយាទេ ទាំងពួកភរិយា ក៏មិនប្រព្រឹត្តកន្លងចិត្តយើង ពួកយើងប្រព្រឹត្តនូវព្រហ្មចរិយធម៌ លើកលែងតែភរិយាទាំងនោះចេញ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើង មិនស្លាប់ ។

បាណាតិបាតា វិរមាម សព្វេ, លោកេ អទិន្នំ បរិវជ្ជយាម;
អមជ្ជបា នោបិ មុសា ភណាម, តស្មា ហិ អម្ហំ ទហរា ន មីយរេ។

*យើងទាំងអស់គ្នា វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន ក្នុងលោក មិនផឹកទឹក ស្រវឹង មិននិយាយពាក្យកុហក ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើង មិនស្លាប់ ។*

ឯតាសុ វេ ជាយរេ សុត្តមាសុ, មេធាវិនោ ហោន្តិ បហូតបញ្ញា;
ពហុស្សុតា វេទគុនោ ច ហោន្តិ, តស្មា ហិ អម្ហំ ទហរា ន មីយរេ។

*កូនទាំងឡាយ (របស់យើង) កើតក្នុងពួកស្ត្រីដ៏ឧត្តម រមែងជាអ្នកប្រាជ្ញ មានប្រាជ្ញាច្រើន ជាពហុស្សូត ដឹងនូវវេទ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់យើង មិនស្លាប់ ។*

មាតា បិតា ច ភគិនី ភាតរោ ច, បុត្តា ច ទារា ច មយញ្ច សព្វេ;
ធម្មំ ចរាម បរលោកហេតុ, តស្មា ហិ អម្ហំ ទហរា ន មីយរេ។

*មាតាបិតា បងប្អូនស្ត្រី បងប្អូនប្រុស កូន ប្រពន្ធ និងយើងគ្រប់គ្នាប្រព្រឹត្តធម៌ ដើម្បីជាប្រយោជន៍ ក្នុងលោកខាងមុខ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើង មិនស្លាប់ ។*

ទាសា ច ទាស្យោ អនុជីវិនោ ច, បរិចារកា កម្មករា ច សព្វេ;
ធម្មំ ចរន្តិ បរលោកហេតុ, តស្មា ហិ អម្ហំ ទហរា ន មីយរេ។

*ពួកខ្ញុំប្រុស ពួកខ្ញុំស្ត្រី អ្នកចិញ្ចឹមជីវិត ដោយសារអ្នកបម្រើ និងអ្នកធ្វើនូវការងារទាំងអស់ ប្រព្រឹត្តធម៌ ដើម្បីប្រយោជន៍ ក្នុងលោកខាងមុខ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់យើង មិនស្លាប់ ។*

ពាក្យថា ***ពួកយើងប្រព្រឹត្តធម៌*** សេចក្ដីថា ពួកយើងប្រព្រឹត្តធម៌ គឺ កុសលកម្មបទ ១០ អ្នកសិក្សាគប្បីឲ្យពិស្ដារទាំងអស់ថា ពួកយើងមិនសម្លាប់សត្វ សូម្បីតែស្រមោចក្រហម ដោយហោចសូម្បីមានហេតុនៃជីវិតរបស់ខ្លួន ពួកយើងមិនសម្លឹងភណ្ឌៈរបស់អ្នកដទៃដោយលោភចិត្ត ដូច្នេះជាដើម ។ តែមុសាវាទដែលព្រាហ្មណ៍លើកឡើងម្ដងទៀត ដោយអំណាចអកុសលដែលខ្លួនខ្ពស់ថា ឈ្មោះថា បាបដែលបុគ្គលមិនធ្វើដោយមុសាវាទជាដើម រមែងមិនមាន ។ បានឮថា ពួកគេមិនពោលមុសា ដោយហោចទៅសូម្បីតែការលេងសើច ។ ពាក្យថា ***អំពើដ៏លាមក*** បានដល់ កម្មដែលនាំកាន់នរកទាំងអស់ ។ ពាក្យថា ***អំពើមិនប្រសើរ*** សេចក្ដីថា ពួកយើងវៀរកម្មដែលព្រះអរិយៈតិះដៀល មិនល្អ មិនបរិសុទ្ធទាំងអស់ ។ បទថា ***តស្មា ហិ អម្ហំ*** សេចក្ដីថា ហិអក្សរក្នុងបទនោះ ត្រឹមតែជានិបាត អធិប្បាយថា ព្រោះហេតុនោះ ក្មេងទាំងឡាយរបស់ពួកខ្ញុំ ទើបមិនស្លាប់ ដែលឈ្មោះថា អកាលមរណៈក្នុងរវាងចន្លោះ រមែងមិនមានដល់ពួកយើង ។ បាលីថា ***តស្មា អម្ហំ*** ដូច្នេះក៏មាន ។

ពាក្យថា ***ពួកយើងស្ដាប់*** សេចក្ដីថា ពួកយើងស្ដាប់ធម៌ដែលបំភ្លឺពីកុសលរបស់សប្បុរសដែលជាកិរិយវាទ និងស្ដាប់ធម៌ដែលបំភ្លឺពីអកុសលរបស់អសប្បុរស តែពួកយើងជាអ្នកត្រឹមតែស្ដាប់ប៉ុណ្ណោះ មិនពេញចិត្តធម៌របស់អសប្បុរសឡើយ ហើយក៏មិនមានការឈ្លោះ និងវិវាទជាមួយនឹងអសប្បុរសនោះដែរ សូម្បីស្ដាប់ហើយ ប្រព្រឹត្តតាមសប្បុរស មិនប្រព្រឹត្តតាមអសប្បុរស ពួកយើងមិនលះសប្បុរសសូម្បីតែមួយខណៈ លះបាបមិត្រ ពួកយើងជាអ្នកសេពគប់តែកល្យាណមិត្តប៉ុណ្ណោះ ។

ពាក្យថា ***ពួកយើងបានញ៉ាំងពួកសមណព្រាហ្មណ៍*** សេចក្ដីថា ម្នាលព្រាហ្មណ៍ ពួកយើងចិញ្ចឹមសមណព្រាហ្មណ៍ គឺព្រះបច្ចេកពុទ្ធ ដែលមានបាបរម្ងាប់ហើយ មានបាបដែលដកចេញហើយ សមណព្រាហ្មណ៍ដែលតាំងនៅក្នុងធម៌ទាំងអស់ និងជនដ៏សេសមានអ្នកដំណើរ ពួកស្មូម ឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹក ។ ចំណែកគាថានេះក្នុងព្រះបាឡីមកតាមក្រោយដោយគាថាថា ***បុព្វេវ ទានា*** ។

*ពាក្យថា **ពួកយើងមិនប្រព្រឹត្តកន្ទង់ចិត្តករិយាទេ** សេចក្ដីថា ពួកយើងមិនកន្ទង់ចិត្តករិយារបស់ខ្លួន មិនប្រព្រឹត្តមិច្ឆាចារនឹងស្ត្រីខាងក្រៅដទៃ ។ ពាក្យថា **ពួកយើងប្រព្រឹត្តនូវព្រហ្មចរិយធម៌ លើកលែងតែករិយាទាំងនោះចេញ** សេចក្ដីថា ពួកយើងប្រព្រឹត្តព្រហ្មចរិយៈក្នុងស្ត្រីដ៏សេស វៀរលែងករិយារបស់ខ្លួន សូម្បីករិយារបស់ខ្ញុំ ក៏ប្រព្រឹត្តយ៉ាងនោះក្នុងបុរសដ៏សេសដែរ ។*

*ពាក្យថា **កូនទាំងឡាយ (របស់យើង) កើតក្នុងពួកស្ត្រីដ៏ឧត្តម** សេចក្ដីថា កើតក្នុងស្ត្រីដែលឧត្តមដោយសីលល្អ ។ មានសេចក្ដីអធិប្បាយថា បុត្រណារបស់ពួកយើង ដែលកើតក្នុងស្ត្រីដែលឧត្តមដោយការដល់ព្រមដោយសីលនោះ ជាអ្នកមានបញ្ញា ប្រការយ៉ាងនេះ សេចក្ដីស្លាប់ក្នុងវវាង របស់បុត្រទាំងនោះ នឹងមានពីណា សូម្បីព្រោះហេតុនោះ ក្មេងទាំងឡាយក្នុងត្រកូលរបស់ខ្ញុំ ទើបមិនស្លាប់ ។ ពាក្យថា **ពួកយើងប្រព្រឹត្តធម៌** សេចក្ដីថា ពួកយើងប្រព្រឹត្តសុចរិតធម៌ ៣ ដើម្បីប្រយោជន៍ដល់បរលោក ។*

*ក្នុងទីបំផុត ព្រាហ្មណ៍ក៏បានសម្ដែងគុណរបស់អ្នកប្រព្រឹត្តធម៌ ដោយគាថាទាំង ២ នេះថា*

**ធម្មោ ហវេ រក្ខតិ ធម្មចារឹ, ធម្មោ សុចិណ្ណោ សុខមាវហាតិ;**
**ឯសានិសំសោ ធម្មេ សុចិណ្ណេ, ន ទុគ្គតឹ គច្ឆតិ ធម្មចារី។**

*ធម៌រមែងរក្សាអ្នកប្រព្រឹត្តធម៌ដោយពិត ធម៌ដែលសន្សំល្អហើយ រមែងនាំសុខមកឲ្យ នេះជាអានិសង្ស ក្នុងធម៌ដែលសន្សំល្អហើយ បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ ។*

**ធម្មោ ហវេ រក្ខតិ ធម្មចារឹ, ឆត្តំ មហន្តំ វិយ វស្សកាលេ;**
**ធម្មេន គុត្តោ មម ធម្មបាលោ, អញ្ញស្ស អដ្ឋីនិ សុខី កុមារោ។**

***ធម៌រមែងរក្សាអ្នកប្រព្រឹត្តធម៌ ដោយពិត ដូចឆត្រធំ (ការពារ) ក្នុងកាលដែលភ្លៀង ធម្មបាលជាបុត្ររបស់យើង ធម៌គ្រប់គ្រងហើយ ឆ្អឹង (ដែលអ្នកនាំមកនេះ) ជាឆ្អឹងសត្វដទៃ កុមារ (ជាបុត្ររបស់យើង) មានសេចក្ដីសុខនៅឡើយ ។***

*ពាក្យថា **រក្សា** សេចក្ដីថា ធម្មតាធម៌ដែលបុគ្គលរក្សាល្អហើយ រមែងត្រឡប់មករក្សាបុគ្គលដែលប្រព្រឹត្តធម៌នោះវិញ ។ ពាក្យថា **នាំសេចក្ដីសុខមកឲ្យ** សេចក្ដីថា រមែងនាំមនុស្ស-សុខ ទេវសុខ និង និព្វានសុខ មកឲ្យ ។ ពាក្យថា **មិនទៅកាន់ទុគ្គតិ** សេចក្ដីថា មិនទៅកាន់ទុគ្គតិមានប្រភេទនរកជាដើម ។ ព្រាហ្មណ៍ជាបិតាធម្មបាលសម្ដែងថា ម្នាលព្រាហ្មណ៍ ពួកយើងរក្សាធម៌ សូម្បីធម៌ក៏រក្សាពួកយើងដែរ ។ ពាក្យថា **ធម៌គ្រប់គ្រងហើយ** សេចក្ដីថា ធម៌ដែលខ្លួនគ្រប់គ្រងហើយ រមែងគ្រប់គ្រប់ដូចឆត្រធំ ។ ពាក្យថា **ឆ្អឹងសត្វដទៃ** សេចក្ដីថា ឆ្អឹងដែលលោកនាំមកនេះ នឹងជាឆ្អឹងពពែ ឬ សុនខដទៃ លោកចូរបោះឆ្អឹងនោះចោលទៅ កុមារជាបុត្ររបស់ខ្ញុំនោះនៅជាសុខ ។*

*អាចារ្យស្ដាប់ពាក្យនោះហើយ ទើបពោលថា ការមករបស់ខ្ញុំជាមកដោយល្អ នឹងមានផលល្អ មិនមែនឥតផលឡើយ ដូច្នេះគាត់មានសេចក្ដីត្រេកអរ ហើយសូមខមាទោសនឹងបិតារបស់ធម្មបាល រួចហើយពោលថា នេះជាឆ្អឹងពពែ ខ្ញុំនាំមកដើម្បីសាកល្បងនឹងលោក បុត្ររបស់លោកមិនមានរោគ លោកចូរឲ្យធម៌ដែលលោករក្សាហើយនោះដល់ខ្ញុំ ថាយ៉ាងនេះហើយ គាត់សរសេរទុកលើក្រដាស និងនៅក្នុងទីនោះអស់ពីរបីថ្ងៃ ទើបទៅកាន់នគរតក្កសិលាវិញ ឲ្យធម្មបាលសិក្សាសិល្បសាស្ត្រទាំងពួងហើយ បញ្ជូនទៅដោយបរិវារដ៏ធំ ។*

*ព្រះសាស្ដាបាននាំព្រះធម្មទេសនានេះ ដល់ព្រះបាទសុទ្ធោទនមហារាជហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ និងប្រជុំជាតក ក្នុងកាលជាទីបញ្ចប់នៃសច្ចៈ ព្រះរាជាបានតាំងនៅក្នុងអនាគាមិផល ។*

**តទា មាតាបិតរោ មហារាជកុលានិ អហេសុំ** *ព្រះមាតាបិតាក្នុងកាលនោះ បានមកជាមហារាជត្រកូល*

**អាចរិយោ សារិបុត្តោ** *អាចារ្យបានមកជាសារីបុត្រ*

**បរិសា ពុទ្ធបរិសា** *បរិស័ទបានមកជាពុទ្ធបរិស័ទ*

**ធម្មបាលកុមារោ បន អហមេវ អហោសិំ** *បំណែកធម្មបាលកុមារ គឺតថាគតនេះឯង ។*

*ចប់ មហាធម្មបាលជាតក ៕*

*( ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ទសកនិបាត បិដកលេខ ៥៩ ទំព័រ ១៨៦)*

*ថ្ងៃអាទិត្យ ១៣ កើត ខែជេស្ឋ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ២៧ ខែ ឧសភា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយ ស.ជ.វ.ថ.*